# ទំនុកមហាក្សត្រផែនដី

ចំណុចទូទៅដែលគេអាចចាត់ទុកថាជាទំនុកមហាក្សត្រផែនដី ព្រោះទំនុកដំកើងនោះមាន (១) សំដៅទៅលើស្តេច ឬមហាក្សត្រ (២) និយាយពី "ការចាក់ប្រេងតាំង" (លាបប្រេង ឬចាក់ប្រេង) ដោយមានប្រើពាក្យនោះជានាម ឬកិរិយាស័ព្ទ (៣) សំដៅទៅលើឈ្មោះរបស់ស្តេចដាវីឌ។

~~មានទំនុកដំកើង៧សំដៅទៅលើស្តេច (ទំនុកដំកើង ២ ១៨ ២០ ២១ ៤៥ ៧២ ៨៩)~~

~~មានទំនុកដំកើង៦ សំដៅទៅលើ "ការចាក់ប្រេងតាំង" (២ ១៨ ២០ ៤៥ ៨៩ ១៣២)~~

## ទំនុកមហាក្សត្រ

| ទំនុកដំកើង | ២ | ១៨ | ២០ | ២១ | ៤៥ | ៧២ | ៨៩ | ១០១ | ១១០ | ១៣២ | ១៤៤ |
|---|---|---|---|---|---|---|---|---|---|---|---|
| ស្តេច ឬ មហាក្សត្រ | x | x | x | x | x | x | x | O | O | O | O |
| ចាក់ប្រេងតាំង | x | x | x | O | O# | O | x | O | O | x | O |
| ដាវីឌ | O | x | O* | O* | O | O | x | O* | O* | x | x |

<u>**ចំណាំ**</u>

- x មាន
- O មិនមាន
- * មានតែមិនសូវច្បាស់
- # មានជាកិរិយាសព្ទ

## ទំនុកមហាក្សត្រ និងព្រះមេស៊ី

យើងសង្កេតឃើញថា ទំនុកមហាក្សត្រគឺជាប្រភពដ៏ធំនៃសេចក្តីសង្ឃឹមព្រះមេស៊ី។ មាន ព្រះមេស៊ី ("ម្នាក់ដែលត្រូវបានចាក់ប្រេងតាំង") បានមាន៩ដងនៅក្នុង១១ជំពូកនេះ និង២ដងប្រើជាកិរិយាស័ព្ទ (ចាក់ប្រេងតាំង)។ មានកំរិតយល់ដឹងពីរកំរិតនៃទំនុកដំកើង៖ កំរិតប្រវត្តិសាស្ត្រ និងកំរិតអវសាន្ត។ នៅក្នុងកំរិតប្រវត្តិសាស្ត្រ យើងគ្រាន់តែសំដៅទៅលើអត្ថន័យត្រង់ៗ៖ ស្តេចគឺជាស្តេចរបស់អ៊ីស្រាអែល ហើយដាវីឌគឺជាដាវីឌនៅក្នុងប្រវត្តិសាស្ត្រនៅសញ្ញាចាស់។ នៅក្នុងកំរិតអវសាន្តវិញ យើងសំដៅទៅលើបុគ្គលអនាគតកាល៖ ស្តេចគឺជារូបមនុស្សដ៏អស្ចារ្យម្នាក់ ដែលបានតែងតាំងដោយព្រះយេហូវ៉ា ដើម្បីនឹងការងារដ៏អស្ចារ្យ ហើយជាចុងក្រោយនោះ ទ្រង់ជាព្រះមេស៊ី ដែលជាព្រះគ្រីស្ទនៃសញ្ញាថ្មី។

សញ្ញាថ្មីបានដកស្រង់ពីក្រុមទំនុកមហាក្សត្រនេះយ៉ាងតិចចំនួន១៥ដង ចេញពីទំនុកដំកើង ២ (៦ដង) ១៨ ៤៥ និង១១០ (៧ដង)។

នៅពេលដែល អ្នកទំនុកដំកើង ប្រកាសថា "ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ" (ទំនុក. ២:៧) គាត់ចង់សំដៅទៅលើទំនាក់ទំនងដ៏វិសេសរវាងព្រះ និងមហាក្សត្រដែលគ្រងរាជ្យនៅក្រុងយេរូសាឡិម។ ម៉្យាងវិញទៀត នៅពេលសាវ័កប៉ុល ឈរនៅក្នុងសាលាប្រជុំនៃពីស៊ីឌាដើម្បីអធិប្បាយ លោកបានដកស្រង់ខនេះ ហើយនិយាយសំដៅទៅលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ (កិច្ចការ ១៣:៣៣)។

អ្នកសរសេរដំណឹងល្អបានដកស្រង់ ទំនុកដំកើង ១១០:១៖

*"អ្នករាល់គ្នាគិតពីព្រះគ្រីស្ទដូចម្តេច តើទ្រង់ជាព្រះវង្សអ្នកណា នោះគេទូលឆ្លើយថា ជាព្រះវង្សហ្លួងដាវីឌ ទ្រង់មានបន្ទូលសួរទៀតថា ដូច្នេះ ធ្វើដូចម្តេចឲ្យហ្លួងដាវីឌមានបន្ទូល ដោយនូវព្រះវិញ្ញាណ ហៅទ្រង់ជាព្រះអម្ចាស់បាន ដោយថា*

*«ព្រះអម្ចាស់ទ្រង់មានបន្ទូលទៅព្រះអម្ចាស់នៃខ្ញុំថា*
*ចូរឯងអង្គុយខាងស្តាំអញ*
*ទាល់តែអញដាក់ពួកខ្មាំងសត្រូវឯងនៅក្រោមជើងឯង»*

*ដូច្នេះ បើហ្លួងដាវីឌនោះឯង ទ្រង់ហៅព្រះគ្រីស្ទថាជាព្រះអម្ចាស់*
*នោះធ្វើដូចម្តេចឲ្យព្រះគ្រីស្ទធ្វើជាព្រះវង្សទ្រង់បាន?*
*(ម៉ាថាយ ២២:៤២-៤៥; ម៉ាកុស ១២:៣៥-៣៧; លូកា ២០:៤២-៤៤)។*

នៅក្នុងទំនុកដំកើងនេះ ព្រះយេស៊ូវបានឮព្រះអម្ចាស់មួយអង្គនិយាយទៅកាន់ព្រះអម្ចាស់មួយអង្គទៀត ហើយការនេះមិនមានន័យថា ដាវីឌគឺជាព្រះអម្ចាស់ទីពីរនោះទេ ព្រោះព្រះមហាក្សត្រឋានសួគ៌មិនអាចហៅមហាក្សត្រផែនដីថាជា "ព្រះអម្ចាស់"បានឡើយ។ ផ្ទុយទៅវិញ ទំនុកដំកើងនិយាយពីព្រះ។

សាវ័កប៉ុលប្រើទំនុកដំកើង ១៨:៤៩ នៅក្នុងកណ្ឌរ៉ូម ១៥:៩

សាវ័កប៉ុលក៏បានដកស្រង់ ទំនុកដំកើង ២:៧ ហើយប្រកាសថា ៖

*យើងខ្ញុំក៏ប្រាប់ដំណឹងល្អនេះ ដល់អ្នករាល់គ្នា គឺជាសេចក្តីសន្យា ដែលបានតាំងនឹងពួកឰយុកោយើងថា ព្រះបានធ្វើសំរេចតាមសេចក្តីសន្យទ្រង់ ដល់យើងជាពួកនៃពួកឰយកោនោះហើយ ដោយទ្រង់បានប្រោសឲ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ដូមានសេចក្តីចែងទុកមក ក្នុងទំនុកដំកើងបទទី២ថា «ឯងជាកូនអញ អញបានបង្កើតឯងនៅថ្ងៃនេះ»*
*(កិច្ចការ ១៣:៣២-៣៣)*